**សកម្មភាព** ៖ **ល្បែងទុយោមេរោគ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**បុរេគណិត**

រូបរាង និងទំហំ(បញ្ញត្តិរូបរាង និងទំហំ)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(បុរេគណិត)** ប្រាប់ឈ្មោះរាងធរណីមាត្រសមញ្ញ ដែលមានរាងរង្វង់ ចតុកោណកែង និងរាងផ្សេងៗ។

**(សិក្សាសង្គម)** ប្រាប់បានពីរបៀបធ្វើសកម្មភាពបង្កើតបានជារូបភាពផ្សេងៗ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “បិសាចចម្លែកតូចៗ?” ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ទុយោ ក្រដាស កាវស្អិត និងខ្មៅដៃពណ៌

**ការរៀបចំ** ៖ កាត់ទុយោប្រវែងដែលត្រូវការតាមរាងធរណីមាត្រ។ ធ្វើកាវស្អិតនឹងធ្វើទុយោមេរោគឱ្យបានរួចរាល់សម្រាប់បង្ហាញទៅក្មេងៗទាំងអស់ ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងទុយោមេរោគ**ជាមួយកូនៗទាំងអស់គ្នា។
2. បង្ហាញសម្ភារមានដូចជា ទុយោ ក្រដាស កាវស្អិត និងខ្មៅដៃពណ៌ ។
3. បង្ហាញក្មេងៗពីរូបភាពដែលអ្នកបានបង្កើតរួចដែលមានរាងធរណីមាត្រដូចជា ការេ ចតុកោណកែង ត្រីកោណកែង គូប ចតុកោណស្មើ…។
4. ឱ្យក្មេងៗថាតាម។

5. ពិពណ៌នាពីរូបរាងរបស់វាដូចជា៖ ត្រីកោណមានជ្រុង ៣ ការេមានជ្រុង ៤ស្មើគ្នា...។
6. បង្ហាញពួកគេពីរបៀបធ្វើទុយោមេរោគដោយមានរាងផ្សេងៗពីគ្នា។
7. បែងចែកសម្ភារឱ្យទៅក្មេងៗទាំងអស់ ឱ្យអនុវត្តផ្ទាល់។
8. ជួយក្មេងៗណាដែលត្រូវការជំនួយពីអ្នកបានតាមដែលអាចធ្វើទៅបាន។
9. ឱ្យក្មេងទាំងអស់រៀបចំសម្ភារឱ្យបានស្អាត និងមានរបៀបនៅពេលដែលចប់ការលេងល្បែងហ្នឹងជាការស្រេច។

**ការប្រែប្រួល៖**

ក្មេងប្រើលេងធ្វើជារូបរាងអ្វីក៏បានដែរ ដូចជា៖ រូបរាងជា បាល់ ផ្លែឈើ ឬសង់ជារូបផ្ទះក៏បានដែរ។

**<u>ការសាងសង់ជារូបរាង</u>**

**តម្រូវការ៖** ទុយយោ សំឡីត្បាល់ត្រចៀក កន្ត្រៃ

**ការបង្ហាត់បង្រៀន៖** កាត់ទុយយោដើម្បីសម្រេចប្រវែងរបស់វា។ សង់វារួមគ្នាដោយប្រើសំឡីត្បាល់ត្រចៀក និងទុយយោ

**កម្មវិធីសិក្សា៖** ចិត្តចលភាព, បុរេគណិត, វិទ្យាសាស្ត្រ



